**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ..០១..សរ....

# សារាចរ

## ស្តីពី

## ការធ្វើជំរឿនមន្ត្រីរាជការស៊ីវិល

ចាប់តាំងពីនីតិកាលទី១ នៃរដ្ឋសភា ឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ននេះ ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលបានដំណើរការធ្វើជំរឿនមន្ត្រីរាជការស៊ីវិលចំនួន២លើករួចមកហើយ គឺលើកទី១ នៅឆ្នាំ ១៩៩៥ និងលើកទី២ នៅឆ្នាំ ១៩៩៩-២០០១។ តាមរយៈលទ្ធផលនៃការធ្វើជំរឿនទាំងពីរលើកនេះ គណៈកម្មការជំរឿនមន្ត្រីរាជការបានរកឃើញមន្ត្រីដែលមានតែឈ្មោះក្នុងក្របខ័ណ្ឌ និងក្នុងបញ្ជីបើកបៀវត្ស(មន្ត្រីខ្មោច) ព្រមទាំងមន្ត្រីមិនប្រក្រតីផ្សេងៗទៀតជាច្រើន ហើយរាជរដ្ឋាភិបាលបានសម្រេចលុបឈ្មោះមន្ត្រីទាំងនោះ ចេញពីក្របខ័ណ្ឌ និងពីតារាងទូទាត់បៀវត្សចំនួន ១៧ ៦៨៥ នាក់ នៅលើកទី១ និង ៩ ៨១៤ នាក់បន្ថែមទៀតនៅលើកទី២ ដែលធ្វើឱ្យរដ្ឋចំណេញថវិកាយ៉ាងច្រើនក្នុងមួយឆ្នាំៗ។ម្យ៉ាងទៀត ផ្តើមចេញពីលទ្ធផលនៃការធ្វើជំរឿនកន្លងមក មូលដ្ឋានទិន្នន័យមន្ត្រីរាជការស៊ីវិលទូទាំងប្រទេសត្រូវបានកសាងឡើង និងប្រើប្រាស់ជាឧបករណ៍សម្រាប់ពង្រឹងការគ្រប់គ្រងរហូតមកដល់សព្វថ្ងៃនេះ។

ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងចំនួនមន្ត្រីរាជការស៊ីវិលឱ្យបានហ្មត់ចត់ និងធានាបានប្រសិទ្ធភាពការងារ និងគណនេយ្យភាពក្នុងរដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលបានសម្រេចឱ្យក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រៀបចំធ្វើជំរឿនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេស ដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា និងមន្ត្រីជាប់កិច្ចសន្យាដែលកំពុងបម្រើការងារនៅតាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

គណៈកម្មការអន្តរក្រសួងមួយនឹងត្រូវបង្កើតឡើង ដើម្បីអនុវត្តប្រតិបត្តិការជំរឿន ក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។ ប្រតិបត្តិការជំរឿនមន្ត្រីរាជការស៊ីវិលមានបីផ្នែក គឺ៖

ទី១-ការរាប់មន្ត្រីរាជការៈ នឹងធ្វើឡើងជាលក្ខណៈរូបវន្ត ហើយតម្រូវឱ្យមន្ត្រីរាជការមានវត្តមានដោយផ្ទាល់នៅតាមទីកន្លែងកំណត់សម្រាប់ការធ្វើប្រតិបត្តិការជំរឿន។

ទី២-ការចែកអត្តសញ្ញាណប័ណ្ណមន្ត្រីៈ មន្ត្រីរាជការគ្រប់រូបដែលមានវត្តមានក្នុងពេលរាប់ នឹងទទួលបានអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការថ្មីរបស់ខ្លួន សម្រាប់ប្រើប្រាស់។

ទី៣-ការបំពេញព័ត៌មានសម្រាប់ធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការ ដែលជាផ្នែកមួយនៃការធ្វើជំរឿនៈ

នៅពេលចុះប្រតិបត្តិការជំរឿន មន្ត្រីរាជការស៊ីវិលគ្រប់រូបនឹងត្រូវបានផ្តល់ជូនកម្រងសំណួរដែលរៀបចំឡើង ដោយគណៈកម្មការជំរឿន និងតម្រូវឱ្យបំពេញព័ត៌មានផ្ទាល់ខ្លួនចាំបាច់មួយចំនួន។

ដើម្បីធានាឱ្យបានជោគជ័យនូវប្រតិបត្តិការជំរឿននេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយគណៈកម្មការជំរឿនមន្ត្រីរាជការស៊ីវិល ដោយត្រូវផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ និងច្បាស់លាស់ដល់មន្ត្រីរាជការក្នុងក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទរបស់ខ្លួន អំពីយុទ្ធនាការជំរឿនមន្ត្រីរាជការស៊ីវិល និងត្រូវចាត់តាំងតំណាងជាមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រងបុគ្គលិក ឱ្យចូលរួមសម្របសម្រួលក្នុងប្រតិបត្តិការជំរឿន និងចូលរួមទទួលខុសត្រូវក្នុងការចុះហត្ថលេខាលើរបាយការណ៍បូកសរុបលទ្ធផលជំរឿន នៅតាមក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន។

ទទួលបានសារាចរនេះ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងក្រុមប្រឹក្សារាជធានីខេត្តទាំងអស់ ត្រូវយកអស់ស្មារតីទទួលខុសត្រូវ និងសហការអនុវត្តការងារនេះឱ្យទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ